# កម្រងសិទ្ធិ នៃអ្នកបោះឆ្នោត

## ★ អ្នកមានសិទ្ធិនៅខាងក្រោម ★

1. **សិទ្ធិដើម្បីបោះឆ្នោត បើសិនអ្នកជាអ្នកបោះឆ្នោតបានចុះឈ្មោះ។** អ្នកមានសិទ្ធិបោះឆ្នោត បើសិនអ្នក៖
   - ★ ជាពលរដ្ឋអាមេរិក កំពុងរស់នៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ា
   - ★ មានអាយុយ៉ាងតិចបំផុត 18 ឆ្នាំ
   - ★ បានចុះឈ្មោះនៅកន្លែងដែលអ្នករស់នៅបច្ចុប្បន្ន
   - ★ បច្ចុប្បន្នមិនបម្រើរដ្ឋឬជាប់ពន្ធនាគារសហព័ន្ធសម្រាប់ការកាត់ទោសពីបទឧក្រិដ្ឋមួយ,និង
   - ★ នៅពេលបច្ចុប្បន្ននេះ មិនបានរកឃើញដោយតុលាការថាអសមត្ថភាពខាងផ្លូវចិត្ត ដើម្បីបោះឆ្នោតឡើយ

2. **សិទ្ធិដើម្បីបោះឆ្នោត បើអ្នកជាអ្នកបោះឆ្នោតបានចុះឈ្មោះ សូម្បីតែឈ្មោះរបស់អ្នកមិននៅក្នុងបញ្ជីក៏ដោយ។**
   អ្នកនឹងបោះឆ្នោតដោយប្រើសន្លឹកឆ្នោតបណ្ដោះអាសន្ន។ ឆ្នោតរបស់អ្នកនឹងបានរាប់ បើមន្ត្រីបោះឆ្នោត សំរេចថាអ្នកមានសិទ្ធិបោះឆ្នោត។

3. **សិទ្ធិដើម្បីបោះឆ្នោត បើអ្នកនៅតែឈរក្នុងជួរ នៅពេលកន្លែងបោះឆ្នោតបិទ។**

4. **សិទ្ធិដើម្បីបោះសន្លឹកឆ្នោតសំងាត់** ដោយគ្មានអ្នកណាម្នាក់រំខានដល់អ្នក ឬប្រាប់អ្នកពីរបៀបបោះឆ្នោត។

5. **សិទ្ធិដើម្បីទទួលសន្លឹកឆ្នោតថ្មី បើអ្នកបានធ្វើដោយភាន់ច្រឡំ** បើអ្នកមិនទាន់បានបោះសន្លឹកឆ្នោតរបស់អ្នកនៅឡើយ។ អ្នកអាច៖
   **ស្នើសុំមន្ត្រីបោះឆ្នោត នៅកន្លែងបោះឆ្នោត** នូវសន្លឹកឆ្នោតថ្មី,
   **ដូរសន្លឹកឆ្នោត បោះឆ្នោត-តាម-សំបុត្រ របស់អ្នក** សំរាប់សន្លឹកឆ្នោតថ្មី នៅឯការិយាល័យបោះឆ្នោត ឬនៅឯកន្លែងបោះឆ្នោតរបស់អ្នក, ឬ
   **បោះឆ្នោតដោយប្រើសន្លឹកឆ្នោតបណ្ដោះអាសន្ន។**

6. **សិទ្ធិដើម្បីទទួលជំនួយ ក្នុងការបោះសន្លឹកឆ្នោតរបស់អ្នក** ពីជនណាម្នាក់ដែលអ្នកជ្រើសរើស លើកលែងតែពីនិយោជក ឬអ្នកតំណាងសហជីពរបស់អ្នក។

7. **សិទ្ធិដើម្បីប្រគល់សន្លឹកឆ្នោត បោះឆ្នោត-តាម-សំបុត្រ របស់អ្នក ដែលបានបំពេញនៅកន្លែងបោះឆ្នោតណាមួយ** ក្នុងរដ្ឋកាលីហ្វ័រនីញ៉ា។

8. **សិទ្ធិដើម្បីទទួលសំភារៈការបោះឆ្នោត ជាភាសាមួយក្រៅពីអង់គ្លេស** បើមានប្រជាជនគ្រប់គ្រាន់នៅក្នុងតំបន់បោះឆ្នោតរបស់អ្នក និយាយភាសានោះ។

9. **សិទ្ធិដើម្បីសួរសំណួរទៅមន្ត្រីបោះឆ្នោត អំពីទំរង់ការបោះឆ្នោត** និងឃ្លាំមើលដំណើរការបោះឆ្នោត។ បើមនុស្សដែលអ្នកសួរ មិនអាចឆ្លើយសំណួររបស់អ្នកបានទេ គេត្រូវតែបញ្ជូនអ្នកទៅមនុស្សត្រឹមត្រូវដែលអាចឆ្លើយសំណួរបាន។ បើអ្នកមានឫកពាអុកឡុក គេអាចឈប់ឆ្លើយសំណួរអ្នក។

10. **សិទ្ធិដើម្បីរាយការណ៍សកម្មភាពខុសច្បាប់អ្វីមួយ ឬការបោះឆ្នោតដោយតែបន្លំ** ទៅមន្ត្រីបោះឆ្នោត ឬការិយាល័យរបស់រដ្ឋលេខាធិការ។

### កំណត់ពិសេស

- កន្លែងបោះឆ្នោតគឺបើកពីម៉ោង 7:00 ព្រឹក ដល់ម៉ោង 8:00 យប់ នៅថ្ងៃបានបង្ហាញនៅក្នុងព័ត៌មានណែនាំអ្នកបោះឆ្នោត ដែលខោនធីបានបិទប្រកាស។
- សេចក្ដីណែនាំជាក់លាក់អំពីរបៀបបោះឆ្នោត រួមទាំងរបៀបបោះឆ្នោត នូវសន្លឹកឆ្នោតបណ្ដោះអាសន្ន អាចទទួលបានពីអ្នកធ្វើការនៅកន្លែងបោះឆ្នោត ឬដោយអានព័ត៌មានដែលបានផ្ញើឲ្យអ្នកដោយមន្ត្រីបោះឆ្នោត តាមមូលដ្ឋានរបស់អ្នក។
- បើសិនអ្នកជាអ្នកបោះឆ្នោតបានចុះឈ្មោះថ្មោងថ្មី អ្នកនឹងបានសូមឲ្យផ្ដល់អត្តសញ្ញាណត្រឹមត្រូវ ឬឯកសារផ្សេងទៀត ស្របទៅតាមច្បាប់ សហព័ន្ធ។ ប៉ុន្តែសូមចំណាំ ថាបុគ្គល គ្រប់ៗរូបសុទ្ធតែមានសិទ្ធិបោះឆ្នោតនូវសន្លឹកឆ្នោតបណ្ដោះអាសន្ន ទោះបើគាត់មិនផ្ដល់ឯកសារក៏ដោយ។
- វាជាការល្មើសនឹងច្បាប់ ដើម្បីបង្ហាញខ្លួនឯងថាមានសិទ្ធិបោះឆ្នោត លុះត្រាតែអ្នកស្របតាមសេចក្ដីតម្រូវទាំងអស់ ដើម្បីបោះឆ្នោត នៅក្រោមច្បាប់សហព័ន្ធ និងរដ្ឋ។
- វាជាការល្មើសនឹងច្បាប់ ដើម្បីអុកឡុកដល់ឧបករណ៍បោះឆ្នោត។

**បើអ្នកជឿថាអ្នកត្រូវបានបដិសេធនូវសិទ្ធិណាមួយទាំងនេះ** ទូរស័ព្ទទៅលេខពិសេសអ្នកបោះឆ្នោតរបស់រដ្ឋលេខាធិការ តាមលេខឥតចេញថ្លៃជាសំងាត់ (888) 345-4917។

គេហ៍ទំព័រ នៅ **www.sos.ca.gov**

តាមទូរស័ព្ទ លេខ **(888) 345-4917**

តាមអ៊ីមែល **elections@sos.ca.gov**